**EMBASSY OF JAPAN**
**IN THE KINGDOM OF CAMBODIA**

# PRESS RELEASE

No. 38 PR-23/EoJ 8 November 2023

## Japan Provides US$348,919 for Constructing Primary School Buildings and Installing Water Supply System

The Government of Japan will provide US$348,919 in total for three recipient organizations under the framework, *the Grant Assistance for Grassroots Human Security Projects ("KUSANONE" Grant)*. The Grant Contracts were signed today between H.E. Mr. UENO Atsushi, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representatives of the three recipients, to carry out the following project.

1. 'The Project for Construction of Sre Ken Primary School Building in Aoral District, Kampong Speu Province' (US$92,425)
Recipient: Kampong Speu Provincial Department of Education, Youth and Sport
In this project, a five-room school building equipped with school furniture, a three-room toilet and a handwashing facility will be built at Sre Ken Primary School in Kampong Speu Province. Currently, students at this school have difficulties in studying because the wooden school building, and wooden furniture are in poor condition. And there is less hygienic environment by the lack of hand washing facility and toilet. This project aims to bring about the safer and more comfortable learning environment, and it is expected to benefit around 149 students and 4 teachers through the improvement in the quality of education.

2. 'The Project for Construction of Russei Douch Primary School Building in Prasat Balang District, Kampong Thom Province' (US$100,344)
Recipient: Kampong Thom Provincial Department of Education, Youth and Sport
In this project, a six-room school building equipped with school furniture and a handwashing facility will be built at Russei Douch Primary School in Kampong Thom Province. Currently, students at this school have difficulties in studying because the current wooden school building, and wooden furniture are in poor condition. And there is less hygienic environment by the lack of hand washing facility. This project aims to bring about the safer and more comfortable learning environment, and it is expected to benefit around 162 students and 8 teachers through the improvement in the quality of education.

3. ‘The Project for Installation of Water Supply System in Senmonorom District, Mondulkiri Province’ (US$156,150)
Recipient: Mondulkiri Water Utility
In this project, water supply system will be constructed and approximately 26km water distribution networks will be installed in Senmonorom City in Mondulkiri Province. Most of the people living in this area have difficulty accessing to safe drinking water and are facing health risks due to the lack of water supply facility within the city. Through this project, more than 2,500 people will have an access to affordable clean water and adequate sanitation, which will contribute to the improvement in their living standard.

Japan’s *“KUSANONE” Projects* started in Cambodia in 1991 in order to support Cambodia’s reconstruction and development at the grassroots level. The assistance aims to protect those who are vulnerable due to various factors such as poverty and/or misfortunes that directly threaten their lives, livelihood, and dignity, as well as to promote self-reliance of local communities. Since 1991, the Government of Japan has provided over US$68 million for mainly local authorities and non-governmental organizations to implement 681 *KUSANONE* projects throughout Cambodia.

---

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023-217-161, fax: 023-214-330*
*Email:* eco.jpn@pp.mofa.go.jp
*Website: http://www.kh.emb-japan.go.jp*

**ស្ថានទូតជប៉ុន**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**
# សេចក្តីប្រកាសព័ត៌មាន

លេខ. 38 PR-23/EoJ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២៣

## ជប៉ុនផ្តល់ថវិកា ៣៤៨,៩១៩ ដុល្លារអាមេរិក សម្រាប់ការសាងសង់អគារសិក្សានៅសាលាបឋមសិក្សា និងការដំឡើងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាសរុបចំនួន **៣៤៨,៩១៩ ដុល្លារអាមេរិក** ដល់ស្ថាប័នទទួលជំនួយចំនួនបី ក្រោមគ្រោងការណ៍ ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយឥតសំណងគូសាណូណេ)។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ **ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី** ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង អ្នកតំណាងស្ថាប័នទទួលជំនួយទាំងបី ដើម្បីអនុវត្តគម្រោងខាងក្រោម៖

**១. គម្រោងសាងសង់អគារសិក្សានៅសាលាបឋមសិក្សាស្រែគិនក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ (ថវិកាចំនួន ៩២,៤២៥ ដុល្លារអាមេរិក)**

ស្ថាប័នទទួលជំនួយ៖ មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ

ក្នុងគម្រោងនេះ អគារសិក្សា១ខ្នង ៥បន្ទប់ បំពាក់ដោយគ្រឿងសង្ហារឹម បង្គន់អនាម័យ១ខ្នង ៣បន្ទប់ និងកន្លែងលាងដៃចំនួន១ នឹងត្រូវបានសាងសង់នៅសាលាបឋមសិក្សាស្រែគិន ក្នុងខេត្តកំពង់ស្ពឺ។ បច្ចុប្បន្ន សិស្សនៅសាលានេះមានការលំបាកក្នុងការសិក្សា ដោយសារអគារសិក្សាឈើ និងគ្រឿងសង្ហារឹមធ្វើអំពីឈើ មានសភាពទ្រុឌទ្រោម។ មិនតែប៉ុណ្ណោះ បរិស្ថានមិនសូវមានអនាម័យ ដោយសារកង្វះកន្លែងលាងដៃ និងបង្គន់។ គម្រោងនេះមានគោលបំណងនាំមកនូវបរិស្ថានសិក្សាដែលមានសុវត្ថិភាព និងផាសុកភាពជាងមុន ហើយយើងរំពឹងថាគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់សិស្សចំនួន ១៤៩ នាក់ និងគ្រូបង្រៀនចំនួន ៤ នាក់ តាមរយៈការកែលម្អគុណភាពអប់រំ។

**២. គម្រោងសាងសង់អគារសិក្សានៅសាលាបឋមសិក្សាប្ញស្សីដួចក្នុងស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ (ថវិកាចំនួន ១០០,៣៨៤ ដុល្លារអាមេរិក)**

ស្ថាប័នទទួលជំនួយ៖ មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ

ក្នុងគម្រោងនេះ អគារសិក្សា១ខ្នង ៦បន្ទប់ បំពាក់ដោយគ្រឿងសង្ហារឹម និងកន្លែងលាងដៃចំនួន១

នឹងត្រូវបានសាងសង់នៅសាលាបឋមសិក្សាឬស្សីជ្រូក ក្នុងខេត្តកំពង់ធំ។ បច្ចុប្បន្ន សិស្សនៅសាលានេះ មានការលំបាកក្នុងការសិក្សា ដោយសារ អគារសិក្សាឈើបច្ចុប្បន្ន និងគ្រឿងសង្ហារឹមធ្វើអំពីឈើ មានសភាពទ្រុឌទ្រោម។ មិនតែប៉ុណ្ណោះ បរិស្ថានមិនសូវមានអនាម័យ ដោយសារកង្វះកន្លែងលាងដៃ។ គម្រោងនេះមានគោលបំណងនាំមកនូវបរិស្ថានសិក្សាដែលមានសុវត្ថិភាព និងផាសុកភាពជាងមុន ហើយយើងរំពឹងថាគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់សិស្សចំនួន ១៦២ នាក់ និងគ្រូបង្រៀនចំនួន ៨ នាក់ តាមរយៈការកែលម្អគុណភាពអប់រំ។

**<u>៣. គម្រោងដំឡើងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី</u>**
**<u>(ថវិកាចំនួន ១៥៦,១៥០ ដុល្លារអាមេរិក)</u>**

*<u>ស្ថាប័នទទួលជំនួយ៖ រដ្ឋាករទឹកមណ្ឌលគិរី</u>*

ក្នុងគម្រោងនេះ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនឹងត្រូវបានសាងសង់ ហើយបណ្តាញចែកចាយទឹកស្អាតប្រមាណ ២៦ គីឡូម៉ែត្រ នឹងត្រូវបានដំឡើងនៅក្នុងក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។ ប្រជាជនភាគច្រើនដែលរស់នៅក្នុងតំបន់នេះ ជួបការលំបាកក្នុងការទទួលបានទឹកបរិភោគដែលមានសុវត្ថិភាព និងកំពុងប្រឈមមុខនឹងហានិភ័យសុខភាព ដោយសារកង្វះបរិក្ខារផ្គត់ផ្គង់ទឹកស្អាតនៅក្នុងទីក្រុង។ តាមរយៈគម្រោងនេះ ប្រជាជនប្រមាណ ២,៥០០ នាក់ នឹងទទួលបានទឹកស្អាតដែលមានតម្លៃសមរម្យ និងអនាម័យគ្រប់គ្រាន់ ដែលនឹងរួមចំណែកដល់ការកែលម្អកម្រិតជីវភាពរស់នៅរបស់ពួកគេ។

ជំនួយឥតសំណងគូសាណូណិរបស់ជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញ នៅកម្រិតមូលដ្ឋាន។ ជំនួយឥតសំណងនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង/ឬ ភាពអកុសលនានា ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់អាយុជីវិត ជីវភាពរស់នៅ និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកា ជាង៦៨លានដុល្លារអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណិចំនួន ៦៨១ គម្រោង នៅទូទាំងប្រទេសកម្ពុជា៕

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*
*គេហទំព័រ៖ http://www.kh.emb-japan.go.jp*

សុន្ទរកថារបស់ **ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី**
ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២៣

សូមគោរព

- **លោក ថន ថារិន** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ
- **លោក តាន់ ប៊ុនហុង** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ
- **លោក សូរ សុវណ្ណារិទ្ធ** អគ្គនាយករដ្ឋាករទឹកមណ្ឌលគិរី
- លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី។

សូមស្វាគមន៍មកកាន់ស្ថានទូតជប៉ុន។ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ គូសាណូណេ នាថ្ងៃនេះ។

ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបាននិងកំពុងផ្តល់ជំនួយឥតសំណងនេះនៅកម្ពុជា ដើម្បីជួយដោយផ្ទាល់ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលនានា ដែលកំពុងអនុវត្តគម្រោង។ គូសាណូណេ មានន័យថា "ឫសស្មៅ" ក្នុងភាសាជប៉ុន។ នៅក្នុងរយៈពេលជាង៣០ឆ្នាំចុងក្រោយនេះ ស្ថានទូតជប៉ុន បានចូលរួមចំណែកក្នុងគម្រោងចំនួន ៦៨១ នៅទូទាំងប្រទេសកម្ពុជា តាមរយៈគ្រោងការណ៍ជំនួយឥតសំណងគូសាណូណេ។ យើងមានសេចក្តីសោមនស្សរីករាយដែលគម្រោងទាំងនេះ បានចូលរួមចំណែកដោយផ្ទាល់ក្នុងការកែលម្អគុណភាពជីវិតរបស់ប្រជាជនកម្ពុជានៅកម្រិតមូលដ្ឋាន។

ថ្ងៃនេះ ខ្ញុំសូមណែនាំគម្រោងដែលបានចុះហត្ថលេខា ដូចខាងក្រោម៖

សម្រាប់គម្រោងទី១ ដែលអនុវត្តដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ៩២,៤២៥ ដុល្លារអាមេរិក (កៅសិបពីរពាន់បួនរយម្ភៃប្រាំដុល្លារអាមេរិក) សម្រាប់ការសាងសង់អគារសិក្សា១ខ្នង ៥បន្ទប់ បំពាក់ដោយគ្រឿងសង្ហារឹម បង្គន់អនាម័យ១ខ្នង ៣បន្ទប់ និងកន្លែងលាងដៃចំនួន១ នៅសាលាបឋមសិក្សាស្រែកិន ក្នុងខេត្តកំពង់ស្ពឺ។ យើងរំពឹងថាគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់សិស្សចំនួន ១៤៩ នាក់ និងគ្រូបង្រៀនចំនួន ៤ នាក់ តាមរយៈការកែលម្អគុណភាពអប់រំ។

សម្រាប់គម្រោងទី២ ដែលអនុវត្តដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ១០០,៣៨៤ ដុល្លារអាមេរិក (មួយរយពាន់បីរយសែសិបបួនដុល្លារអាមេរិក) សម្រាប់ការសាងសង់អគារសិក្សា១ខ្នង ៦បន្ទប់ បំពាក់ដោយគ្រឿងសង្ហារឹម និងកន្លែងលាងដៃចំនួន១ នៅសាលាបឋម

សិក្សាឬស្សីជ្រួច ក្នុងខេត្តកំពង់ធំ។ យើងរំពឹងថាគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់សិស្សចំនួន ១៦២ នាក់ និងគ្រូបង្រៀនចំនួន ៨ នាក់ តាមរយៈការកែលម្អគុណភាពអប់រំ។

សម្រាប់គម្រោងទី៣ ដែលអនុវត្តដោយរដ្ឋាករទឹកមណ្ឌលគិរី រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ១៥៦,១៥០ ដុល្លារអាមេរិក (មួយរយហាសិបប្រាំមួយពាន់មួយរយហាសិបដុល្លារអាមេរិក) សម្រាប់ការសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងការដំឡើងបណ្តាញចែកចាយទឹកស្អាតប្រមាណ ២៦ គីឡូម៉ែត្រ ក្នុងក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។ យើងរំពឹងថាគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណ ២,៥០០ នាក់ តាមរយៈការកែលម្អកម្រិតជីវភាពរស់នៅរបស់ពួកគេ។

ខ្ញុំមានសេចក្តីសោមនស្សរីករាយដោយសង្កេតឃើញថានាពេលថ្មីៗនេះ ប្រទេសកម្ពុជា បាននិងកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័ស។ ទោះយ៉ាងណា ខ្ញុំក៏ទទួលស្គាល់ថានៅតែមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយដើម្បីកែលម្អគុណភាពជីវិតរបស់ប្រជាជន។ ជប៉ុន នឹងបន្តចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ តាមរយៈគ្រោងការណ៍ជំនួយអភិវឌ្ឍន៍ផ្លូវការផ្សេងៗ រួមទាំង ជំនួយគូសាណូណិ ផងដែរ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី សូមមានសុខភាពល្អ សុភមង្គល និងសូមឱ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។

សូមអរគុណ៕